# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត និងការគ្រប់គ្រង

## តំបន់សេដ្ឋកិច្ចពិសេស

*****

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីសារពើពន្ធ និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញក្រឹត្យ ក្រុមប្រឹក្សារដ្ឋ នៃរដ្ឋកម្ពុជា លេខ ៩៧ ក្រ. ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល

- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១៖ គោលដៅ និង ការអនុវត្តនៃអនុក្រឹត្យ

១.១ គោលដៅ

អនុក្រឹត្យនេះ មានគោលដៅ បង្កើត និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនឹងបង្កើននូវបរិយាកាសវិនិយោគ ដែលអំណោយផលដល់ការធ្វើឱ្យកាន់តែប្រសើរនូវផលិតភាពក្នុងការផលិតទំនិញ ការប្រជែងឈ្នះ កំណើនសេដ្ឋកិច្ចជាតិ ជម្រុញការនាំចេញ ដោះស្រាយការងារជូនប្រជាជនដើម្បីកាត់បន្ថយភាពក្រីក្រ ព្រមជាមួយគ្នានេះ កំណត់អំពី នីតិវិធី និងបទប្បញ្ញត្តិទាំងឡាយទាក់ទងដល់ការបង្កើត ការគ្រប់គ្រង សម្របសម្រួលរាល់សកម្មភាពវិនិយោគ និងជម្រុញលើកទឹកចិត្តដល់ការវិនិយោគរបស់អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ផ្អែកលើគោលដៅខាងលើនេះ រាជរដ្ឋាភិបាលនឹងលើកស្ទួយតំបន់សេដ្ឋកិច្ចពិសេស ដើម្បីអនុវត្តន៍នូវគោលការណ៍និងលក្ខខណ្ឌ ដែលធានាបាននូវតម្លាភាពនិងប្រតិបត្តិការរហ័ស គណនេយ្យភាពចំពោះអ្នកវិនិយោគ ការទទួលបាននូវភាព្រូវការអំពីព័ត៌មាន និងភាពស៊ីចង្វាក់គ្នាទៅជាមួយនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចុះកន្លងមក។

១.២ ការអនុវត្ត

អនុក្រឹត្យនេះ ត្រូវដាក់ឱ្យអនុវត្តចំពោះរាល់សកម្មភាពរបស់ ក្រសួង ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ដែលមានភារកិច្ចពាក់ព័ន្ធ អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់សេដ្ឋកិច្ច

ពិសេសទាំងអស់ ដែលបានទទួលការអនុញ្ញាតឱ្យចុះបញ្ជីវិនិយោគ និងទទួលបាននូវការលើកទឹកចិត្តនានា និងការធានាលើការវិនិយោគ ពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងពីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។

## មាត្រា ២ៈ និយមន័យ

ក្នុងន័យនៃអនុក្រឹត្យនេះ វាក្យស័ព្ទបច្ចេកទេសដូចខាងក្រោម ÷

ក្រុមប្រឹក្សា សំដៅដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបង្កើតឡើងតាមមាត្រា ៣នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា សំដៅដល់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាចំណុះឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលបានបង្កើតឡើងតាមអនុក្រឹត្យ នឹងដែលមានភារកិច្ចលើការសម្រេចឱ្យបង្កើត និងធ្វើការដឹកនាំគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សំដៅដល់គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

តំបន់សេដ្ឋកិច្ចពិសេស សំដៅដល់មជ្ឈមណ្ឌលពិសេសសម្រាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ដែលប្រមូលផ្តុំនូវសកម្មភាពឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀត ហើយអាចមានតំបន់ឧស្សាហកម្មទូទៅ ឬ និងតំបន់ផលិតកែច្នៃនាំចេញ ។ តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ ត្រូវមានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន និងមណ្ឌលទេសចរណ៍ ។

តំបន់ឧស្សាហកម្មទូទៅ សំដៅដល់តំបន់មួយដែលបង្កើតឡើង សម្រាប់សកម្មភាពឧស្សាហកម្ម និងសកម្មភាពដទៃទៀត ដែលពាក់ព័ន្ធនឹងការផលិតទំនិញ ការកែច្នៃទំនិញសម្រាប់បម្រើសេចក្តីត្រូវការនៃទីផ្សារក្នុងស្រុក ឬនិងសម្រាប់នាំចេញ ។

តំបន់ផលិតកែច្នៃនាំចេញ សំដៅដល់តំបន់នៃសកម្មភាពឧស្សាហកម្ម និង សកម្មភាពដទៃទៀតដែលពាក់ព័ន្ធនឹងការផលិត ការកែច្នៃទំនិញសម្រាប់បម្រើតែការនាំចេញប៉ុណ្ណោះ។

ធាតុចូលផលិតកម្ម សំដៅដល់ ទំនិញ រួមបញ្ចូលទាំងវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្ម ដែលត្រូវបានបំប្លែងឬត្រូវបានប្រើប្រាស់

យ៉ាង ពេញលេញនៅក្នុងកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនឱ្យហួសពីរយៈពេល ២(ពីរ)ឆ្នាំ បន្ទាប់ពីបាននាំចូល ។ និយមន័យនេះ មិនគិតបញ្ចូលផងទេ នូវសម្ភារៈ និងគ្រឿងសង្ហារឹមសម្រាប់ប្រើប្រាស់ក្នុងការិយាល័យ ផលិតផលគេលសិលា យានយន្ត និងគ្រឿងបន្លាស់យានយន្ត ។

ធាតុចេញផលិតកម្ម សំដៅដល់ទំនិញ ដែលបានផលិតចេញពីធាតុចូលផលិតកម្ម និងដែលត្រូវបានបំប្លែង ។

មណ្ឌលផលិតកម្ម សំដៅដល់ មណ្ឌលប្រមូលផ្តុំរោងចក្រដែលស្ថិតនៅក្នុងតំបន់ឧស្សាហកម្ម ។

មណ្ឌលពាណិជ្ជកម្មសេរី សំដៅដល់ មណ្ឌលសម្រាប់សកម្មភាពផ្គត់ផ្គង់សេវាកម្ម ស្តុក ដាក់តាំង វេចខ្ចប់ សម្អាត ឬបង្ហើយការ នូវធាតុចេញផលិតកម្ម ផលិតផល សម្ភារៈបរិក្ខារ ឬសម្ភារៈដទៃទៀត ដែលការនាំចេញពី ឬនាំចូលមកក្នុងតំបន់ត្រូវបានលើកលែងពន្ធ លើកលែងតែការនាំចេញទៅទីកន្លែងផ្សេងទៀតនៃទឹកដីព្រះរាជាណាចក្រកម្ពុជា ដែលការនាំចូល និងនាំចេញនោះ ត្រូវទទួលរងនូវកាតព្វកិច្ចពន្ធគយ និងអាករ ទៅតាមច្បាប់ធរមាន ។

មណ្ឌលសេវាកម្ម សំដៅដល់ មណ្ឌលសម្រាប់គាំទ្រសកម្មភាពឧស្សាហកម្ម និងពាណិជ្ជកម្មដូចជា ការិយាល័យចាត់ចែង និងប្រតិបត្តិការរបស់តំបន់ឧស្សាហកម្ម ធនាគារ ប្រៃសណីយ៍ អាគារលក់ទំនិញប្រចាំថ្ងៃ និងសេវាកម្មមធ្យោបាយដឹកជញ្ជូននានាផ្សេងៗទៀត។

មណ្ឌលលំនៅដ្ឋាន សំដៅដល់ មណ្ឌលសម្រាប់ការស្នាក់អាស្រ័យរបស់ កម្មករ និយោជិត និងនិយោជក នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សំដៅដល់ អង្គភាពគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋ ដែលជាយន្តការច្រកចេញចូលតែមួយនៅនឹងកន្លែងនៃតំបន់សេដ្ឋកិច្ចពិសេស និងមានភារកិច្ចចេញនូវលិខិតអនុញ្ញាត ការយល់ព្រម អាជ្ញាប័ណ្ណ និងបញ្ជីការ រួមទាំងការអនុម័តលើការលើកទឹកចិត្តនានាជំនួសមុខឱ្យសាមីក្រសួង ស្ថាប័នជំនាញ តាមការទទួលសិទ្ធិអំណាចពេញលេញរបស់ក្រសួង និងស្ថាប័នសាមីសម្រាប់ផ្តល់ជូនដល់អ្នកវិនិយោគក្នុងតំបន់ជាមួយគ្នាដោះស្រាយនូវរាល់សំណូមពរនានាពាក់ព័ន្ធនឹងសមត្ថកិច្ចគ្រប់គ្រងរបស់រដ្ឋក្នុងដំណើរការវិនិយោគនៅក្នុងតំបន់។

សម្ភារៈបរិក្ខារផលិតកម្ម សំដៅដល់ គ្រឿងម៉ាស៊ីន ឧបករណ៍ ដែលបានប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងការបំប្លែងធាតុចូលផលិតកម្ម ហើយដែលវត្ថុទាំងនោះមិនអាចបំប្លែងដោយខ្លួនឯង ឬ ត្រូវបានប្រើប្រាស់អស់ក្នុងរយៈពេល ២(ពីរ) ឆ្នាំ បន្ទាប់ពីបាននាំចូល ។ គ្រឿងម៉ាស៊ីន និង ឧបករណ៍ទាំងនោះ មិនត្រូវគិតបញ្ចូលផងទេ នូវឧបករណ៍ ផ្នែកព័ត៌មានវិទ្យា ឬយានយន្តដែលប្រើប្រាស់សម្រាប់គោលបំណងផ្សេង ក្រៅពីកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

អ្នកអភិវឌ្ឍន៍តំបន់ សំដៅដល់ អ្នកអនុវត្តន៍គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទោះជារូបវន្តបុគ្គលឬនីតិបុគ្គលសញ្ជាតិខ្មែរក្តី ឬនិងបរទេសក្តី ដែលបានទទួលការអនុញ្ញាតឱ្យធ្វើការវិនិយោគទុនដើម្បីអភិវឌ្ឍន៍សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅក្នុងតំបន់និងចាត់តាំងការធ្វើអាជីវកម្ម សេវាកម្ម ផ្តល់សុវត្ថិភាពផ្នែកសន្តិសុខនានា បំរើឱ្យអ្នកវិនិយោគក្នុងតំបន់។

អ្នកវិនិយោគក្នុងតំបន់ សំដៅដល់ អ្នកអនុវត្តន៍គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទោះជារូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរក្តី ឬនិងបរទេសក្តី ដែលបានទិញឬជួលអចលនទ្រព្យពីអ្នកអភិវឌ្ឍន៍តំបន់ ហើយធ្វើសកម្មភាពវិនិយោគ ក្នុងការងារអាជីវកម្មផលិតផលិតកម្ម សេវាកម្ម ពាណិជ្ជកម្ម នៅក្នុងតំបន់នោះ។

## ជំពូកទី ២

## នីតិវិធីនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស

### មាត្រា ៣ៈ ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស

៣.១ លក្ខខណ្ឌនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស÷

១- តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុញ្ញាតឱ្យបង្កើតឡើងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានៅតាមតំបន់សមស្រប និងប្រកបដោយយុទ្ធសាស្ត្រតាមការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយអនុលោមតាមស្មារតីសម្រេចចិត្តរបស់យន្តការច្រកចេញ ចូលតែមួយនៃក្រុមប្រឹក្សា។

២-តំបន់សេដ្ឋកិច្ចពិសេស អាចផ្តួចផ្តើមបង្កើតឡើងដោយ រដ្ឋ ឬ ឯកជន ឬ រដ្ឋចម្រុះឯកជន។

៣-ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ត្រូវអនុលោមទៅតាមលក្ខខណ្ឌដូចតទៅ÷

(ក) ត្រូវមានទំហំដីចាប់ពី ៥០(ហាសិប) ហិកតាឡើងទៅ ដោយត្រូវមានទីតាំងច្បាស់លាស់

ភូមិសាស្ត្រច្បាស់លាស់។

(ខ) មានរបងព័ទ្ធជុំវិញតំបន់(សម្រាប់តំបន់ផលិតកែច្នៃនាំចេញ និងសម្រាប់មណ្ឌលពាណិជ្ជកម្មសេរី និងតាមគ្រប់ទីតាំងផ្ទាល់របស់អ្នកវិនិយោគ ក្នុងតំបន់នីមួយៗ)។

(គ) មានអាគារការិយាល័យចាត់ចែងការងារ ការិយាល័យរដ្ឋបាលតំបន់ មានប្រព័ន្ធផ្លូវគមនាគមន៍ទូលាយ តូច ធំ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធអគ្គិសនី បណ្តាញប្រៃសណីយ៍ និងទូរគមនាគមន៍ និងប្រព័ន្ធការពារសុវត្ថិភាពទប់ទល់នឹងអគ្គិភ័យជាយថាហេតុ។ផ្អែកទៅតាមលទ្ធភាពនិងស្ថានភាពជាក់ស្តែង តំបន់អាចមានដីបម្រុងទុក សម្រាប់មណ្ឌលលំនៅដ្ឋានរបស់កម្មករ និយោជិត និងនិយោជក មានសួនលំហែកាយ មានគិលានដ្ឋាន សាលាបណ្តុះបណ្តាលមុខជំនាញ ស្ថានីយប្រេងឥន្ធនៈ ភោជនីយដ្ឋាន ចំណតយានយន្ត អាគារលក់ទំនិញ ឬផ្សារ។ល។

(ឃ) មានប្រព័ន្ធបង្ហូរទឹកសំអុយ ប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតសំណល់រាវ មានទីតាំងទុកដាក់ និងគ្រប់គ្រងសំណល់រឹងត្រឹមត្រូវ មានបរិធានការពារបរិស្ថាន និងបណ្តាហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធដទៃទៀត តាមស្ថានភាពជាក់ស្តែងនូវតម្រូវការ។

(ង) លក្ខណៈបច្ចេកទេស បទប្បញ្ញត្តិ និងបទដ្ឋានជាមូលដ្ឋាននានា បម្រើឱ្យការសាងសង់កិច្ចការបរិស្ថាន និងកិច្ចការជំនាញផ្សេងៗទៀត សម្រាប់ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសជាមូលដ្ឋានខាងលើនេះ ត្រូវមានការកំណត់ ណែនាំដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ចជំនាញ តាមរយៈការចងក្រងជាបទដ្ឋានទៅតាមច្បាប់ និងស្តង់ដាជាតិ និងអន្តរជាតិ ផ្អែកតាមភូមិសាស្ត្រ និងទំហំជាក់ស្តែងនៃតំបន់នីមួយៗ។

៣.២ នីតិវិធីនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស÷

១- អ្នកអភិវឌ្ឍន៍តំបន់ទាំងឡាយ ដែលមានបំណងចង់បណ្តាក់ទុនធ្វើការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងភូមិសាស្ត្រណាមួយ ត្រូវធ្វើសំណើសុំគោលការណ៍អភិវឌ្ឍន៍តំបន់មកគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុនសិន។ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានភារកិច្ចធ្វើការសន្និដ្ឋានលើសំណើ ហើយលើកយោបល់ដាក់ជូនកិច្ចប្រជុំច្រកចេញចូលតែមួយនៃក្រុមប្រឹក្សា ដើម្បីធ្វើការសម្រេចផ្តល់គោលការណ៍ ឬបដិសេធគោលការណ៍សុំបង្កើតតំបន់ ។

អ្នកអភិវឌ្ឍន៍តំបន់ ត្រូវបង់ថ្លៃដាក់ពាក្យសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅពេលដាក់ពាក្យចំនួន

៧ ០០០ ០០០ រៀល(ប្រាំពីរលានរៀល)ជូនគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ។

២- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ត្រូវឆ្លើយតបអំពីលទ្ធផលជាវិជ្ជមាន ឬអវិជ្ជមាន របស់សំណើក្នុងរយៈពេលយ៉ាងយូរបំផុត ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការជូនទៅអ្នកអភិវឌ្ឍន៍តំបន់វិញ។

៣- អ្នកអភិវឌ្ឍន៍តំបន់ ដែលបានទទួលគោលការណ៍ឱ្យអភិវឌ្ឍន៍ពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាអាចមានពេលចំនួន១៨០(មួយរយប៉ែតសិប)ថ្ងៃនៃថ្ងៃធ្វើការ និងអាចពន្យាបានក្នុងករណីមានមូលហេតុច្បាស់លាស់ដើម្បីធ្វើគម្រោងសិក្សាសមិទ្ធិលទ្ធភាពសេដ្ឋកិច្ចលម្អិត ដែលរួមមានការបង្ហាញនូវប្លង់មេ ស្តីពីបណ្តាហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ ផ្លូវគមនាគមន៍ភ្ជាប់ពីក្នុងតំបន់មកក្រៅ ប្រព័ន្ធទឹក-ភ្លើង ប្រព័ន្ធការពារបរិស្ថាន តម្លៃសេវាកម្មនានាក្នុងតំបន់ តម្លៃជួលដីជួលរោងចក្រ ទឹក ភ្លើង ទូរស័ព្ទ សន្តិសុខ និងតម្លៃប្រើប្រាស់ទីលានសាធារណៈក្នុងតំបន់របស់អ្នកវិនិយោគក្នុងតំបន់ សម្រាប់កម្មករ និយោជិត និយោជកស្នាក់នៅ និងមណ្ឌលបណ្តុះបណ្តាល។ល។ និងឯកសារពាក់ព័ន្ធនានាឬលិខិតបញ្ជាក់ផ្សេងៗទៀតដែលគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា តម្រូវទៅតាមសំណូមពររបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច ដោយតម្រូវការទាំងនោះត្រូវកំណត់នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌជូនអ្នកអភិវឌ្ឍន៍តំបន់ ។

៤- ក្នុងរយៈពេលយ៉ាងយូរ ១០០ (មួយរយ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអ្នកអភិវឌ្ឍន៍តំបន់ដាក់គម្រោងជូនគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដូចមានចែងក្នុងកថាខ័ណ្ឌ ៣.២ ចំណុច ៣ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ត្រូវទទួលយក ជំនួសមុខឱ្យអ្នកអភិវឌ្ឍន៍តំបន់នូវ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានាពីក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចឬភ្នាក់ងារ ដែលមានការពាក់ព័ន្ធផ្សេងៗរបស់រាជរដ្ឋាភិបាល ដែលមានភារកិច្ចផ្តល់ឯកសារទាំងនេះ ព្រមជាមួយគ្នានូវការចេញជូនវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរដល់អ្នកអភិវឌ្ឍន៍តំបន់ តាមការកំណត់នៃកថាខ័ណ្ឌនេះ ។

៥- ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងព្រំដែនខ័ណ្ឌសីមារបស់តំបន់សេដ្ឋកិច្ចពិសេសនីមួយៗនឹងត្រូវកំណត់ដោយអនុក្រឹត្យ ស្របពេលដែលគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាផ្តល់វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរជូនអ្នកអភិវឌ្ឍន៍តំបន់ ។

៦- អ្នកអភិវឌ្ឍន៍តំបន់ ដែលមិនបានអនុវត្តគម្រោងយ៉ាងតិច ៣០ (សាមសិប) ភាគរយនៃទុនវិនិយោគសរុប ក្នុងរយៈពេល៣៦៥ (បីរយហុកសិបប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលទទួល

បាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានសិទ្ធិដកហូតមកវិញនូវគោលការណ៍អភិវឌ្ឍន៍តំបន់ ការលើកទឹកចិត្តនានា ដែលបានផ្តល់ជូនតាមរយៈវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរកន្លងមក។

៣.៣- នីតិវិធីសម្រាប់ការចុះបញ្ជីរបស់អ្នកវិនិយោគក្នុងតំបន់÷

បុគ្គលជាអ្នកវិនិយោគក្នុងតំបន់ ដែលចាប់ផ្តើមធ្វើសកម្មភាព ផលិតកម្ម ឬសេវាកម្មក្នុងវិស័យដែលច្បាប់ និងអនុក្រឹត្យពាក់ព័ន្ធអនុញ្ញាតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសណាមួយ ត្រូវបំពេញបែបបទតាមនីតិវិធី ដោយត្រូវរៀបចំឯកសារពាក្យស្នើសុំចុះបញ្ជីវិនិយោគ នៅការិយាល័យរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដែលមានភារកិច្ចសម្រេចលើការចុះបញ្ជីនៃសំណើវិនិយោគទាំងលើទិដ្ឋភាពច្បាប់ រដ្ឋបាល និងមុខជំនាញនៅរៀងរាល់ម៉ោងធ្វើការ ដើម្បីទទួលបាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរស្របតាមនីតិវិធីនៃការចុះបញ្ជីវិនិយោគដែលកំណត់ដោយច្បាប់និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

ការលើកទឹកចិត្តវិនិយោគ ដែលអ្នកវិនិយោគក្នុងតំបន់មានសិទ្ធិទទួលបាន ត្រូវសម្រេចដោយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស តាមយន្តការច្រកចេញ ចូលតែមួយ នៅនឹងកន្លែងរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

រាល់សំណើផ្សេងៗទៀតក្នុងកិច្ចដំណើការរបស់អ្នកវិនិយោគតំបន់ រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសបំពេញតួរនាទីជាអ្នកសម្របសម្រួលក្នុងការដោះស្រាយជូនអ្នកវិនិយោគក្នុងតំបន់ ជាមួយក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលតាមមុខជំនាញ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធគ្រប់គ្រង និង ភារកិច្ច

### មាត្រា ៤: រចនាសម្ព័ន្ធគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

៤.១ គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស:

គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស មានភារកិច្ចដោះស្រាយជាបន្ទាន់នូវរាល់កិច្ចការទាំងឡាយដែលកើតមាននៅតាមតំបន់សេដ្ឋកិច្ចពិសេសទាំងលើទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពច្បាប់ ឬដែលមានលក្ខណៈស្ថិតក្នុងសមត្ថកិច្ចចម្រុះត្រូវដោះស្រាយដោយអន្តរក្រសួង

ឬអន្តរស្ថាប័ន ហើយដែលហួសពីលទ្ធភាពសម្រេចរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ឬរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

ក្រៅពីនោះគណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេសក៏ទទួលភារកិច្ច ជាយន្តការទទួលពាក្យតវ៉ា និងដោះស្រាយសំណើតវ៉ានោះ ពីសំណាក់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ផងដែរ។

គណៈកម្មាធិការនេះ មានទីតាំងនៅទីស្នាក់ការក្រុមប្រឹក្សា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាក្នុងកិច្ចការងាររបស់ខ្លួន។

សមាសភាពរបស់គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេសមានដូចតទៅ ÷

| | | |
|---|---|---|
| ១- | សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសហប្រធាន |
| ២- | រដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- | រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- | រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម | សមាជិក |
| ៥- | រដ្ឋមន្ត្រីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៧- | រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួង សាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៩- | រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០- | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១- | អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា | ជាលេខាធិការ |

ក្នុងករណីចាំបាច់ គណៈកម្មាធិការនេះអាចអញ្ជើញ សមាជិកណាមួយនៃក្រុមប្រឹក្សា ដើម្បីចូលរួមប្រជុំ នៅរាល់កិច្ចប្រជុំរបស់គណៈកម្មាធិការនេះ។ សម័យប្រជុំរបស់គណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេសប្រព្រឹត្តទៅ តាមការកោះអញ្ជើញប្រជុំរបស់លេខាធិការរបស់គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេសផ្អែកតាមការកំណត់ណែនាំរបស់សហប្រធាននៃគណៈកម្មាធិការនេះ។

៤.២ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា÷

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ជាច្រកចេញចូលតែមួយ ក្នុងការទទួលបន្ទុកលើការអភិវឌ្ឍន៍ ការគ្រប់គ្រង ការត្រួតពិនិត្យ នៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចពិសេស។ ភារកិច្ចរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាគឺ÷

១- ធ្វើជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើរាល់ការងារពាក់ព័ន្ធនឹងគោលនយោបាយ យុទ្ធសាស្រ្ត លើកគម្រោងផែនការ និងកំណត់ទិសដៅ សម្រាប់ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- កំណត់គោលការណ៍ និងបទប្បញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធដល់ការងារតែងតាំងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ការចាត់តាំងយន្តការច្រកចេញចូលតែមួយនៅក្នុងតំបន់ ការគ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅនៃដំណើរការរបស់តំបន់ ការដោះស្រាយទំនាស់និងការរំលាយតំបន់ជាយថាហេតុ។

៣- អនុវត្តផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ និងមិនមែនសារពើពន្ធ ដល់អ្នកអភិវឌ្ឍន៍តំបន់ និងណែនាំគោលការណ៍នៃការលើកទឹកចិត្តរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ផ្តល់ជូនដល់អ្នកវិនិយោគក្នុងតំបន់ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

៤- រៀបចំគោលការណ៍ណែនាំអំពីការងារគ្រប់គ្រង និងការបណ្តុះបណ្តាលពលករ ការងារបរិស្ថាន ការងារសំណង់ ការនាំចេញ នាំចូល ការទទួលបាននូវការលើកទឹកចិត្តវិនិយោគ និងកិច្ចការជំនាញផ្សេងៗ ទៀតរួមទាំងការបង្កលក្ខណៈងាយស្រួលក្នុងកិច្ចទំនាក់ទំនង ជាមួយក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីធានាឱ្យកិច្ចការរបស់តំបន់សេដ្ឋកិច្ចពិសេសប្រព្រឹត្តទៅមានភាពរលូន និងមានប្រសិទ្ធភាព ។

៥- ធ្វើការងារអធិការកិច្ច លើរាល់សកម្មភាពមិនប្រក្រតីរបស់តំបន់ ។

៦- ដោះស្រាយរាល់សំណូមពរពាក់ព័ន្ធនឹងផលប្រយោជន៍របស់ អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់ កម្មករ និយោជិត និយោជក និងបណ្តឹសំណូមពរបច្ចេកទេស និងច្បាប់ផ្សេងៗ ។

៤.៣ រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស÷

គឺជាយន្តការច្រកចេញចូលតែមួយ ដែលរៀបចំដោយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាដើម្បីប្រចាំការជាអចិន្ត្រៃយ៍នៅតាមតំបន់សេដ្ឋកិច្ចពិសេសនីមួយៗ និងមានរចនាសម្ព័ន្ធ និងរបបការងារដូចតទៅ÷

១- សមាសភាពរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសមាន÷

- តំណាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ជាប្រធាន
- តំណាងទីចាត់ការគយ និងរដ្ឋាករ សមាជិក
- តំណាងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំ សមាជិក
- តំណាងក្រសួងពាណិជ្ជកម្ម សមាជិក
- តំណាងក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

សមាសភាពមន្ត្រីខាងលើនេះ ត្រូវតែងតាំងដោយក្រសួង ស្ថាប័នសាមីដើម្បីឱ្យទៅប្រចាំការជាអចិន្ត្រៃយ៍នៅតាមតំបន់នីមួយៗ នៅពេលដែលតំបន់នោះចាប់ផ្តើមដំណើរការ។

២- ការិយាល័យធ្វើការរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសគឺជាបន្ទុករបស់អ្នកអភិវឌ្ឍន៍តំបន់ ក្នុងការផ្តល់ឱ្យនូវការិយាល័យធ្វើការ ដោយផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ ទឹកភ្លើង កន្លែងសម្រាក និងការឧបត្ថម្ភនានាទៅតាមលទ្ធភាពជាក់ស្តែង ។ល។

៣- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធខាងលើ ត្រូវធ្វើប្រតិភូកម្មសិទ្ធិអំណាចគ្រប់គ្រាន់ជូនតំណាងរបស់ខ្លួនក្នុងការសម្រេចការងារជួសមុខឱ្យក្រសួង និងស្ថាប័ន ស្របទៅតាមសមត្ថកិច្ចរៀងៗខ្លួននៅក្នុងតំបន់។

៤- ប្រាក់បៀវត្ស របស់មន្ត្រីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ត្រូវបើកនៅតាមអង្គភាពដើម ។

៥- រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនីមួយៗ មានត្រាមួយដោយឡែកសម្រាប់ប្រើប្រាស់ជាផ្លូវការលើរាល់លិខិតស្នាមទាំងអស់ បំរើឱ្យការងាររបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។

ភារកិច្ចរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសគឺ÷

(ក) ត្រួតពិនិត្យតាមមុខជំនាញសមត្ថកិច្ចចំពោះការចេញពី និងចូលមកនូវទំនិញ មធ្យោបាយ និងជនានុជនគ្រប់រូបរបស់តំបន់ ។ អនុវត្តន៍ការត្រួតពិនិត្យបែបបទគយសម្រាប់ការចេញ ចូលទំនិញ និង សម្រួលបែបបទរដ្ឋបាលដល់កិច្ចដំណើរការរបស់តំបន់ជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចជំនាញនានា របស់រាជរដ្ឋាភិបាល។

(ខ) ត្រួតពិនិត្យ ការអនុវត្តការងាររបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់លើរាល់សកម្មភាពនៅក្នុងតំបន់ ដោយផ្អែកតាមគោលការណ៍ដែលបានកំណត់ ។

(គ) ពិនិត្យលើសំណើសុំចុះបញ្ជីវិនិយោគ ពិនិត្យផ្តល់ជូនការលើកទឹកចិត្ត ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ វិញ្ញាបនប័ត្រប្រភពដើមទំនិញដែលស្នើឡើងដោយអ្នកវិនិយោគក្នុងតំបន់ ដើម្បីធ្វើការសម្រេចជូនអ្នកវិនិយោគក្នុងតំបន់នៅនឹងកន្លែង។

(ឃ) ធ្វើការត្រួតពិនិត្យការងារ សកម្មភាពតាមមុខជំនាញនៅក្នុងតំបន់ ។

(ង) សហការជាមួយអ្នកអភិវឌ្ឍន៍តំបន់ ដោះស្រាយការងារដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

(ច) សម្រួលរាល់បែបបទ ដែលពាក់ព័ន្ធអោយបានឆាប់រហ័ស និងមានប្រសិទ្ធភាព ។

(ឆ) ធ្វើរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ឆមាស និង ឆ្នាំ ពីសកម្មភាពរបស់តំបន់ ជូនក្រសួង ស្ថាប័នគ្រប់គ្រង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង។

(ជ) ធ្វើកិច្ចការផ្សេងៗទៀតក្នុងការសម្របសម្រួល ដោះស្រាយរាល់សំណើ របស់អ្នកវិនិយោគក្នុងតំបន់ ពាក់ព័ន្ធទៅនឹងបណ្តាក្រសួង ស្ថាប័ននានា របស់រាជរដ្ឋាភិបាល។

៤.៤ អ្នកអភិវឌ្ឍន៍តំបន់ ÷

អ្នកអភិវឌ្ឍន៍តំបន់ ធ្វើសកម្មភាពស្ថិតនៅក្រោមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

អ្នកអភិវឌ្ឍន៍តំបន់មានភារកិច្ចៈ

(ក) ត្រូវមានទុន និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ រួមទាំងធនធានមនុស្សដើម្បីដឹកនាំសកម្មភាពនៃតំបន់។

(ខ) ត្រូវមានដីធ្លី និង មានសិទ្ធិកាន់កាប់ស្របច្បាប់ ដើម្បីបង្កើតតំបន់។

(គ) ធ្វើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់រួមមាន ការសាងសង់ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹកស្អាត ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធថែរក្សា និងគ្រប់គ្រងបរិស្ថានរួមនៃតំបន់ សាងសង់ ឃ្លាំងផ្ទុកទំនិញ ស្ថានីយការពារអគ្គីភ័យ និងសំណង់សេវាកម្មផ្សេងៗទៀត ដែលជាតម្រូវការចាំបាច់នៅក្នុងតំបន់។

(ឃ) ជួលដី ផ្តល់សេវានានា ដល់អ្នកវិនិយោគក្នុងតំបន់ កំណត់ថ្លៃឈ្នួល និងថ្លៃសេវាដែលបានផ្តល់ជូនអ្នកវិនិយោគក្នុងតំបន់ រួមមានតម្លៃ ទឹក អគ្គិសនី អាគារ ប្រព័ន្ធទូរគមនាគមន៍ អនាម័យតាមទីសាធារណៈរបស់តំបន់ កម្លាំងសន្តិសុខ និងមធ្យោបាយផ្សេងៗដែលទទួលបំរើដល់ដំណើរការប្រចាំថ្ងៃរបស់អ្នកវិនិយោគក្នុងតំបន់។

(ង) រៀបចំចាត់ចែងកងកម្លាំងសន្តិសុខយាមកាម និងធានានូវសណ្តាប់ធ្នាប់ល្អនៅក្នុងតំបន់ជាប្រចាំ ២៤ ម៉ោងលើ ២៤ម៉ោង។

(ច) រៀបចំបទប្បញ្ញត្តិនានា ដែលទាក់ទងដល់ការងារសេវាកម្មក្នុងតំបន់រួមមានបទបញ្ជាផ្ទៃក្នុងតំបន់ វិន័យទូទៅរបស់អ្នកវិនិយោគក្នុងតំបន់ និងកំណត់មុខសញ្ញាអាជីវកម្ម ផលិតកម្ម សេវាកម្ម ដែលទទួលឱ្យបោះទីតាំងក្នុងតំបន់តាមគោលការណ៍កំណត់ ឱ្យធ្វើសកម្មភាពក្នុងតំបន់។

(ឆ) ធ្វើការឃោសនាទាក់ទាញអ្នកវិនិយោគឱ្យមកធ្វើការវិនិយោគក្នុងតំបន់ និងផ្តល់ព័ត៌មានលំអិតស្តីពីបែបបទ នីតិវិធី និងផលប្រយោជន៍ដែលអ្នកវិនិយោគត្រូវទទួលបានក្នុងការធ្វើវិនិយោគ នៅក្នុងតំបន់របស់ខ្លួន ។

(ជ) ធ្វើការថែទាំ និងជួសជុលបណ្តាហេដ្ឋារចនាសម្ព័ន្ធ ធានាបាននូវគុណភាព និងអនាម័យត្រឹមត្រូវ និងទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់លើរាល់សកម្មភាពមិនប្រក្រតី និងការអនុវត្តខុសពីគោលការណ៍កំណត់របស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

(ឈ) ធ្វើរបាយការណ៍ជូន គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា តាមការតម្រូវ និងអនុវត្តកាតព្វកិច្ចពន្ធដារជូនរដ្ឋ តាមរយៈការកាន់បញ្ជីគណនេយ្យច្បាស់លាស់តាមគំរូណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

(ញ) សហការណ៍ និងផ្តល់ការឧបត្ថម្ភនានា ដល់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសក្នុងកិច្ចដំណើរការរបស់តំបន់ និងមានទំនាក់ទំនងជិតស្និទ្ធជាមួយរដ្ឋអំណាចមូលដ្ឋានដើម្បីដោះស្រាយការងារ ដែលមានការពាក់ព័ន្ធ។

## ជំពូកទី ៤
## ការលើកទឹកចិត្តសម្រាប់តំបន់សេដ្ឋកិច្ចពិសេស

### មាត្រា ៥: នីតិវិធីនៃការលើកទឹកចិត្ត

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាពិនិត្យ និងផ្តល់ការលើកទឹកចិត្តដល់គ្រប់តំបន់សេដ្ឋកិច្ចពិសេសទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា÷

៥.១- សំណើសុំនាំចូលឧបករណ៍សម្ភារៈបរិក្ខារ សម្ភារៈសាងសង់ ដោយរួចពន្ធ សម្រាប់ការងារសាងសង់តំបន់របស់អ្នកអភិវឌ្ឍន៍តំបន់ ត្រូវដាក់ជូនគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដើម្បីពិនិត្យ និងសម្រេច ។

៥.២- ការលើកទឹកចិត្តលើការនាំចូល សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ត្រូវសម្រេចផ្តល់ជូនដល់អ្នកវិនិយោគក្នុងតំបន់តាមសំណូមពរ និង គោលការណ៍នៃច្បាប់ ដោយសាមីអ្នកវិនិយោគក្នុងតំបន់នោះ ត្រូវរៀបចំបញ្ជីសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្មដែលត្រូវសុំនាំចូលទាំងនោះ ដាក់ជូនរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសពិនិត្យ ដែលនឹងត្រូវសម្រេចផ្តល់ជូននៅនឹងកន្លែង ហើយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសគ្រាន់តែរាយការណ៍ជូនមក គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងស្ថាប័នគ្រប់គ្រង ដើម្បីជ្រាបជាព័ត៌មានប៉ុណ្ណោះ។

៥.៣- សិទ្ធិដែលត្រូវបានទទួលការលើកទឹកចិត្តផ្នែកសារពើពន្ធនឹងសម្រេចជូនអ្នកវិនិយោគក្នុងតំបន់ នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ដែលនឹងត្រូវចេញជូនអ្នកវិនិយោគក្នុងតំបន់ ស្របតាមច្បាប់ និងអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

## មាត្រា ៦: ការលើកទឹកចិត្តផ្នែកសារពើពន្ធ

៦.១ អ្នកអភិវឌ្ឍន៍តំបន់ ត្រូវទទួលបាននូវការលើកទឹកចិត្តទាំងឡាយសម្រាប់សកម្មភាពវិនិយោគដូចតទៅ÷

(ក) ពន្ធលើប្រាក់ចំណេញ: រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ត្រូវបានផ្តល់ជូនសម្រាប់រយៈពេលអតិបរមា ៩ (ប្រាំបួន)ឆ្នាំ ស្របទៅនឹងមាត្រា ១៤ថ្មី ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

(ខ) ពន្ធនាំចូល និងអាករផ្សេងៗ: ការនាំចូលសម្ភារៈបរិក្ខារ សម្ភារៈសាងសង់ ដែលត្រូវប្រើប្រាស់ក្នុងតំបន់សម្រាប់បំរើឱ្យការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ ត្រូវបានអនុញ្ញាតដោយពន្ធនាំចូល និងអាករផ្សេងៗជាបន្ទុករបស់រដ្ឋ ។

៦.២ អ្នកវិនិយោគក្នុងតំបន់នឹងទទួលបាននូវការលើកទឹកចិត្តលើពន្ធគយ និងអាករ ដោយអនុលោមទៅតាមមាត្រា ១៤ថ្មី ចំណុច ១៤.៩ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង បទប្បញ្ញត្តិពាក់ព័ន្ធ ។

៦.៣ អ្នកវិនិយោគក្នុងតំបន់ដែលទទួលបាននូវការលើកទឹកចិត្ត ចំពោះអាករលើតម្លៃបន្ថែមតាមអត្រា ០(សូន្យ)ភាគរយ ត្រូវបានធ្វើការកត់ត្រាទុកនូវប្រាក់ពន្ធដែលបានលើកលែងនេះសម្រាប់ជាលិកហើយ

នាំចូលមួយលើកៗរបស់អ្នកវិនិយោគក្នុងតំបន់ ហើយតួរលេខកត់ត្រាប្រាក់ពន្ធនេះនឹងត្រូវលប់ចោលប្រសិនបើធាតុចេញផលិតកម្មត្រូវបាននាំចេញទៅវិញ។ ក្នុងករណីដែលធាតុចេញផលិតកម្មបានបង្វិលនាំចូលទៅទីផ្សារក្នុងស្រុក អ្នកវិនិយោគក្នុងតំបន់ត្រូវបង់សងវិញនូវអាករលើតម្លៃបន្ថែមនេះវិញតាមចំនួនទឹកប្រាក់ដែលបានកត់ត្រាប្រៀបធៀបទៅនឹងបរិមាណដែលបាននាំចេញ។

## មាត្រា ៧: ការលើកទឹកចិត្តដទៃទៀត

៧.១- អ្នកអភិវឌ្ឍន៍តំបន់ត្រូវទទួលបាននូវការនាំចូលដោយរួចពន្ធចំពោះគ្រឿងចក្រសម្ភារៈបរិក្ខារសម្រាប់ការសាងសង់ផ្លូវដែលតភ្ជាប់ពីទីប្រជុំជនទៅតំបន់ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសម្រាប់សេវាសាធារណៈផ្សេងៗទៀត ដើម្បីផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍របស់តំបន់ផ្ទាល់ ។

៧.២- អ្នកអភិវឌ្ឍន៍តំបន់អាចសុំនាំចូលតាមរូបភាពរួចពន្ធបណ្តោះអាសន្ន (AT) នូវបណ្តា មធ្យោបាយដឹកជញ្ជូន គ្រឿងចក្រ តាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដើម្បីសាងសង់ហេដ្ឋាចនាសម្ព័ន្ធនានាក្នុងដំណើរការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។

៧.៣- ការនាំចូលទាំងអស់របស់អ្នកអភិវឌ្ឍន៍តំបន់និងអ្នកវិនិយោគក្នុងតំបន់ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធស្តីពីអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

៧.៤- អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់ និយោជិតបរទេស មានសិទ្ធិផ្ទេរទៅក្រៅប្រទេសនូវរាល់ប្រាក់ចំណូលពីការវិនិយោគ ប្រាក់បៀវត្ស ដែលទទួលបាននៅក្នុងតំបន់ តាមរយៈធនាគារក្រោយពេលបានបង់ពន្ធរួច។

៧.៥- ក្រៅពីការលើកទឹកចិត្តផ្នែកសារពើពន្ធ អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់ មានសិទ្ធិទទួលបាននូវការធានាវិនិយោគ ដូចមានចែងក្នុងមាត្រា ៨ថ្មី មាត្រា៩ និង មាត្រា១០ថ្មី នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

៧.៦- អ្នកអភិវឌ្ឍន៍តំបន់ អាចទទួលបាននូវដីសម្បទានពីរដ្ឋសម្រាប់បង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅតាមតំបន់ជាប់ព្រំដែន ឬតំបន់ដាច់ស្រយាល ស្របតាមច្បាប់ភូមិបាល ហើយអាចជួលបន្តឱ្យទៅអ្នកវិនិយោគក្នុងតំបន់។

## ជំពូកទី ៥
## វិធានពិសេសទាក់ទងដល់ការគ្រប់គ្រង
## តំបន់ផលិតកែច្នៃនាំចេញនៃតំបន់សេដ្ឋកិច្ចពិសេស

### មាត្រា ៨៖ លក្ខខណ្ឌនៃតំបន់ផលិតកែច្នៃនាំចេញ

តំបន់ផលិតកែច្នៃនាំចេញនៃតំបន់សេដ្ឋកិច្ចពិសេស ជាតំបន់ដែលមានរបងថ្មព័ទ្ធជុំវិញនិងមានច្រកទ្វារចេញ ចូលច្បាស់លាស់ដែលកំណត់ដោយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

មានតែកម្មករ និយោជិត និយោជក ឬភ្ញៀវ និងភ្នាក់ងារមានសមត្ថកិច្ចដែលមានលិខិតអនុញ្ញាតប៉ុណ្ណោះ ទើបអាចធ្វើដំណើរចេញ ចូលក្នុងបរិវេណតំបន់ និងបរិវេណទីតាំងអ្នកវិនិយោគក្នុងតំបន់បាននៅពេលម៉ោងការងារ។ គ្មានបុគ្គលណាម្នាក់ ទោះបីក្នុងឋានៈណាក៏ដោយអាចស្នាក់នៅក្រៅម៉ោងការងារក្នុងបរិវេណតំបន់ផលិតកែច្នៃនាំចេញ និងបរិវេណទីតាំងអ្នកវិនិយោគក្នុងតំបន់បានឡើយ លើកលែងតែជាសមត្ថកិច្ចយាមប្រចាំការ និង បុគ្គលដែលបានទទួលសិទ្ធិពីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។

### មាត្រា ៩៖ ពេលវេលាចេញពី ឬ ចូលក្នុងតំបន់ផលិតកែច្នៃនាំចេញ

ពេលវេលាកំណត់សម្រាប់ការបើកទ្វារឱ្យចេញពី ឬ ចូលក្នុង តំបន់ផលិតកែច្នៃនាំចេញរបស់អ្នកមានភារកិច្ច រាប់ទាំងការនាំចេញ និងការនាំចូលទំនិញ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសតាមរយៈការពិភាក្សាឯកភាពគ្នារវាង អ្នកអភិវឌ្ឍន៍តំបន់ និងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។

### មាត្រា ១០៖ ទំនិញចេញពី ឬ ចូលក្នុងតំបន់កែច្នៃនាំចេញ

ទំនិញដែលធ្វើចរាចរចេញពី ឬ ចូលក្នុង តំបន់ផលិតកែច្នៃនាំចេញ ត្រូវអនុវត្តទៅតាមបទបញ្ជាច្បាស់លាស់ ÷

១០.១-ការនាំទំនិញចេញពី ឬចូលក្នុងបរិវេណតំបន់ផលិតកែច្នៃនាំចេញ ត្រូវបានចាត់ទុកថាជាការនាំទំនិញចេញពី ឬ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា ដែលចាំបាច់ម្ចាស់ទំនិញត្រូវធ្វើការបំពេញបែបបទនាំចេញ នាំចូល ជាមុនជាមួយភ្នាក់ងារមានសមត្ថកិច្ចប្រចាំការនៅតំបន់ផលិពកែច្នៃនាំចេញ។ ទំនិញទាំងនោះ ត្រូវរៀបចំទុកដាក់ វេចខ្ចប់តាមលក្ខណៈបច្ចេកទេស ដោយត្រូវបិទស្លាកត្រឹមត្រូវដោយមន្ត្រីគយ មុននឹងធ្វើការនាំចេញពី ឬនាំចូលក្នុងតំបន់ផលិតកែច្នៃនាំចេញ

១០.២- ភ្នាក់ងារមានសមត្ថកិច្ចក្នុងកិច្ចការខាងលើនេះ ត្រូវរៀបចំនូវទម្រង់បែបបទ ដែលមានភាពសាមញ្ញ ងាយស្រួល មានតម្លាភាព និងមិនបង្កការលំបាកដល់ការត្រួតពិនិត្យទំនិញទាំងនោះឡើយ ។

១០.៣- មិនមានការធ្វើពាណិជ្ជកម្មលក់រាយណាមួយអាចបោះទីតាំង ឬធ្វើសកម្មភាពនៅក្នុងតំបន់ផលិតកែច្នៃនាំចេញបានឡើយ ទោះបីក្រោមរូបភាពបំរើផលប្រយោជន៍សង្គម ឬសាធារណៈក៏ដោយ ។

១០.៤- អ្នកវិនិយោគក្នុងតំបន់ ទោះបីសាមីខ្លួនជាម្ចាស់ក៏ដោយមិនអាចយកធាតុចេញផលិតកម្មដែលផលិតនៅក្នុងតំបន់ផលិតកែច្នៃនាំចេញទៅប្រើប្រាស់ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសបានឡើយ ។

១០.៥- អ្នកវិនិយោគក្នុងតំបន់ផលិតកែច្នៃនាំចេញ អាចស្នើសុំទៅរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដើម្បីធ្វើការទិញទំនិញពីទីផ្សារក្នុងស្រុក ឬពីអ្នកវិនិយោគដែលស្ថិតក្នុងតំបន់ឧស្សាហកម្មទូទៅដើម្បីបំពេញតម្រូវការផលិតកម្ម ដោយត្រូវបំពេញបែបបទកិច្ចសន្យាច្បាស់លាស់ ហើយរាល់ការទិញ លក់នេះត្រូវតែមានការត្រួតពិនិត្យពីភ្នាក់ងារគយប្រចាំតំបន់សេដ្ឋកិច្ចពិសេសទាំងអស់។

ចំពោះការស្នើសុំលក់ចេញទៅទីផ្សារក្នុងស្រុកនូវ ធាតុចេញផលិតកម្ម ដែលខ្វះ ឬខូចគុណភាព ឬជាទំនិញហួសសម័យដែលអ្នកវិនិយោគក្នុងតំបន់មិនអាចធ្វើការនាំចេញបាន ចាំបាច់អ្នកវិនិយោគក្នុងតំបន់ ត្រូវតែលើកសំណើសុំការសម្រេចដូចគ្នាទៅនឹងការសុំទិញចូលមកក្នុងតំបន់ដែរ ។

រាល់ទំនិញដែលបញ្ចេញទៅលក់នៅទីផ្សារក្នុងស្រុក ទោះបីក្នុងស្ថានភាពណាក៏ដោយ ទំនិញនោះត្រូវបំពេញបែបបទដូចជាទំនិញដែលនាំចូលមកព្រះរាជាណាចក្រកម្ពុជា និងត្រូវរងនូវកាតព្វកិច្ចបង់ពន្ធនាំចូល និងអាករផ្សេងៗទៀតជាធរមាន ។

១០.៦- រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស មានសិទ្ធិគ្រប់គ្រាន់ និងគ្រប់ពេលវេលា ដើម្បីធ្វើការឆែកឆេរលើរាល់ករណីសង្ស័យទាំងឡាយណា ដែលទាក់ទងទៅនឹងសកម្មភាពមិនប្រក្រតីរបស់អ្នកវិនិយោគក្នុងតំបន់ ក្នុងការនាំចេញ ឬ នាំចូលប្រសិនបើចាំបាច់ និងត្រូវជូនដំណឹងនេះជាផ្លូវការទៅអ្នកអភិវឌ្ឍន៍តំបន់ និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

១០.៧- រាល់ការរំលោភបំពានរបស់អ្នកវិនិយោគក្នុងតំបន់ណាមួយនៃតំបន់ផលិតកែច្នៃនាំចេញ ទៅលើគោលការណ៍នៃការនាំទំនិញខុសទិសដៅកំណត់ ខុសផែនការគ្រប់គ្រងបរិស្ថាន ការរំលោភលើគោលការណ៍ផលិតកម្ម ការផលិតទំនិញមិនស្របច្បាប់ មិនត្រឹមត្រូវស្របតាមបទដ្ឋានស្តង់ដាផលិតឬការយកផលប្រយោជន៍ដែលរដ្ឋបានផ្តល់ឱ្យទៅប្រើខុសទិសដៅ គឺជាកម្មវត្ថុដែលត្រូវទទួលរងនូវការផាកពិន័យ និងទោសទណ្ឌទៅតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

## ជំពូកទី ៦

## កម្លាំងពលកម្ម

### មាត្រា ១១: ការប្រើប្រាស់ និងការគ្រប់គ្រងកម្លាំងពលកម្ម

ការប្រើប្រាស់ និងការគ្រប់គ្រងកម្លាំងពលកម្មនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានធានានូវសិទ្ធិ និងការការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ កម្មករ និយោជិត ដែលបម្រើការងារនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានទទួលនូវកម្រិតប្រាក់ឈ្នួល សិទ្ធិ និងផលប្រយោជន៍ សុវត្ថិភាពការងារ និងលក្ខខណ្ឌនៃការថែរក្សាសុខភាព ដូចបានកំណត់ក្នុងច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពី ការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

ការជួលអ្នកគ្រប់គ្រង អ្នកបច្ចេកទេស ឬអ្នកជំនាញការពីបរទេសអាចអនុវត្តបាន សម្រាប់តែករណីដែលចំនួនអ្នកបម្រើការងារជាជនជាតិបរទេសនោះ:
មិនមានចំនួនលើសពី១០(ដប់)ភាគរយនៃចំនួនសរុប របស់បុគ្គលិក កម្មករ និយោជិតរបស់ខ្លួនប៉ុណ្ណោះ។

អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់សញ្ជាតិបរទេស អាចនាំយកមកជាមួយនូវសហព័ទ្ធ អ្នកក្នុងបន្ទុករបស់ខ្លួន និងមានសិទ្ធិទទួលបាននូវទិដ្ឋាការស្នាក់នៅ ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា ។

រាល់ការប្រើប្រាស់កម្លាំងពលកម្ម តាមរយៈការជ្រើសរើស និង ជួលកម្មករ និយោជិតខ្មែរ ឬកម្លាំងពលកម្មបរទេស តាមអត្រាកំណត់ខាងលើ និងការនាំយកមកនូវអ្នកក្នុងបន្ទុក ត្រូវអនុវត្ត ឱ្យបានស្របតាមច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីអន្តោប្រវេសន៍ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ជំពូកទី ៧

## ការចារបណ្តុះបណ្តាលវិជ្ជាជីវៈ

### មាត្រា ១២: ការបណ្តុះបណ្តាល

អ្នកអភិវឌ្ឍន៍តំបន់មានភារកិច្ចសហការណ៍ ជាមួយក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កលក្ខណៈបណ្តុះបណ្តាលដល់ កម្មករ និយោជិតខ្មែរ បង្កើនការយល់ដឹងនិងបច្ចេកទេសថ្មីៗដល់កម្មករ និយោជិតទាំងនោះតាមកម្មវិធីច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់។

## ជំពូកទី ៨

## ដំណោះស្រាយវិវាទ និង ការរំលោភបំពាន

**មាត្រា ១៣:**

តំបន់សេដ្ឋកិច្ចពិសេស ដែលបោះទីតាំងនៅលើទឹកដីនៃខេត្ត ក្រុងណាមួយនៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការខេត្ត ក្រុងនោះ សម្រាប់ករណីដែលមានការរំលោភបំពាននានា រួមទាំងករណីបទល្មើសព្រហ្មទណ្ឌដែលកើតមានផង ។

**មាត្រា ១៤:**

អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់ កម្មករ និយោជិត និយោជក និងមន្ត្រីរាជការណាដែលធ្វើសកម្មភាព និងបំពេញការងារនៅក្នុងតំបន់ ហើយបានរំលោភបំពានទៅនឹងបទបញ្ញាទាំងឡាយ ដែលបានកំណត់ក្នុងតំបន់សេដ្ឋកិច្ចពិសេសនោះនឹងត្រូវទទួលរងទោសទណ្ឌ ទៅតាមច្បាប់ជាធរមាន ។

មន្ត្រីរបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសត្រូវហាមឃាត់មិនឱ្យជ្រៀតជ្រែកចូលកិច្ចការអភិវឌ្ឍន៍របស់តំបន់ឡើយ។

បុគ្គលដែលជាមន្ត្រីរាជការ ដែលអនុវត្តខុសពីតួនាទី និងសិទ្ធិអំណាចដែលបានប្រគល់ជូនដោយក្រសួង ស្ថាប័នគ្រប់គ្រង ត្រូវទទួលនូវទោស ស្របទៅតាមមាត្រាទាំងឡាយនៃច្បាប់ស្តីពី សហលក្ខន្តិកៈនៃមន្ត្រីរាជការជាធរមាន។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ១៥:**

បទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ឬបទប្បញ្ញត្តិពាក់ព័ន្ធនានា ត្រូវយកមកអនុវត្តលើរាល់សកម្មភាពនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ក្នុងករណីដែលបញ្ញត្តិនៃអនុក្រឹត្យនេះមិនបានបញ្ជាក់ ។

**មាត្រា ១៦:**

អនុក្រឹត្យនេះ ត្រូវធ្វើបច្ចុប្បន្នភាពទៅតាមសភាពការណ៍ និងតម្រូវការជាក់ស្តែងនៃការអនុវត្ត

តាមសំណើរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងមានការយល់ព្រមពីគណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេស ព្រមជាមួយត្រូវរៀបចំឱ្យទៅជាទម្រង់ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសមួយ ដើម្បីធានាបាននូវតម្លាភាព និងទំនុកចិត្តពីអ្នកវិនិយោគនាពេលដ៏ឆាប់ខាងមុខ។

**មាត្រា ១៧:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន អភិបាលគ្រប់ខេត្ត ក្រុង និងអង្គភាពពាក់ព័ន្ធ ត្រូវទទួល អនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

**<u>កន្លែងទទួល:</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ១៧
-ឯកសារ-កាលប្បវត្តិ